ARPC
analysis•research•planning

1220 19th Street, NW
Suite 700
Washington, D.C.  20036
Phone  (202) 797-1111
Fax      (202) 797-3619

**ឯកសារភ្ជាប់ A៖**

# វិធីសាស្ត្រ ARPC ក្នុងការគណនាទៅលើការទូទាត់ប្រាក់សំណងបណ្តោះអាសន្នសម្រាប់ការខាតបង់ដោយសារការកំពប់ប្រេងនៅឆ្នាំ2011

ថ្ងៃទី16ខែសីហា ឆ្នាំ2011

## I. លក្ខខណ្ឌតម្រូវដែលអ្នកប្ដឹងទាមទារបង្ហាញនូវចំណូលនិង/ឬអត្រាកើនឡើងនៃចំណូលយ៉ាងហោចណាស់ 5% ពីឆ្នាំ2010។

វិធីសាស្ត្រដែលបានស្នើឡើងនេះគឺមានគោលបំណងដើម្បីអនុញ្ញាតឱ្យ GCCF ធ្វើការវាស់វែងផលប៉ះពាល់របស់ការកំពប់ប្រេងកាន់តែមានភាពសុក្រឹតនិងកត្តាផ្សេងៗទៀតទាក់ទងនឹងចំណូលសរុបសម្រាប់ពាណិជ្ជកម្មនិងចំណូលរួមរបស់បុគ្គល។ សម្រាប់ការបាត់បង់នៅឆ្នាំ2010 GCCF ពឹងផ្អែកលើកត្តាគួបផ្សំនៃទីតាំងភូមិសាស្ត្រ ការធ្វើតេស្តផ្នែកហិរញ្ញវត្ថុ និងភស្តុតាងផ្ទាល់ដើម្បីកំណត់ថាតើអ្នកប្ដឹងទាមទារត្រូវបានធ្វើឱ្យខូចប្រយោជន៍ដោយការកំពប់ប្រេងឬទេ។ ប្រសិនបើអ្នកប្ដឹងទាមទារពេញចិត្តនឹងលក្ខខណ្ឌតម្រូវវាត្រូវបានគេសន្មតថាការខូចខាតទាំងឡាយត្រូវបានកើតឡើងដោយការកំពប់ប្រេងហើយអ្នកប្ដឹងទាមទារមានសិទ្ធិ៍ទទួលបាននូវសំណងចំពោះការបាត់បង់ទាំំងនោះ។ ខណៈដែលការធ្វើតេស្តទាំងនេះបន្តជាលក្ខខណ្ឌចាំបាច់សម្រាប់សិទ្ធិទទួលបាន ពួកវាគឺមិនគ្រប់គ្រាន់ដើម្បីធានាថាការខូចខាតបន្តបន្ទាប់របស់អ្នកប្ដឹងទាមទារក្រោយឆ្នាំ2010 គឺបណ្ដាលមកពីការកំពប់ប្រេងឡើយ។ ច្បាស់ណាស់ថាការដែលពេលវេលាចេះតែខិតទៅមុខ វាកាន់តែលំបាកទៅៗដើម្បីកំណត់ថាតើការផ្លាស់ប្ដូរទាំងឡាយនៅក្នុងចំណូលនិងកម្រៃទទួលបានគឺដោយសារតែការកំពប់ប្រេងឬកត្តាផ្សេងៗទៀត។

វិធីសាស្ត្រដ៏សមហេតុផលដើម្បីកំណត់ផលប៉ះពាល់ទៅមុខនៃការកំពប់ប្រេងចំពោះអ្នកប្ដឹងទាមទារគឺត្រូវរំពឹងថាអ្នកប្ដឹងទាមទារបង្ហាញនូវអត្រាកំណើនប្រាក់ចំណូលនិង/ឬកម្រៃយ៉ាងហោចណាស់5% ពីឆ្នាំ2010។ ប្រសិនបើអ្នកប្ដឹងទាមទារបង្ហាញពីអត្រានៃការរីកចម្រើនយ៉ាងតិច5%ពីឆ្នាំ2010 ការខាតបង់ទាំងឡាយនឹងត្រូវបានសន្មតថាកើនឡើងដោយសារការកំពប់ប្រេង។ ប្រសិនបើអ្នកប្ដឹងទាមទារមិនបានបង្ហាញអត្រានៃការរីកចម្រើន 5% នោះទេ នោះការខាតបង់ខ្លះឬទាំងអស់គឺបានកើតឡើងដោយកត្តាផ្សេងៗជាជាងការកំពប់ប្រេង និងមិនត្រូវបានគេទទួលខុសត្រូវឡើយ។ ពាក្យបណ្ដឹងដែលទាមទារដោយអ្នកប្ដឹងទាមទារសម្រាប់សំណងប្រាក់បណ្ដោះអាសន្ន (អ្នកដែលបានដាក់ពាក្យបណ្ដឹងពីមុនសម្រាប់ការខាតបង់ឆ្នាំ2010 និងបានឆ្លងកាត់តេស្តសិទ្ធិអាចទទួលនិងតេស្តហិរញ្ញវត្ថុ) ត្រូវបានគេអនុញ្ញាតឱ្យទទួលនូវសំណងពេញឬ

មួយផ្នែកដោយមិនចាំបាច់ផ្តល់ភស្តុតាងទាក់ទងនឹងការបាត់បង់ដោយសារការកំពប់ប្រេងឡើយ។ នៅពេលដែលអ្នកប្តឹងទាមទារទាំងអស់មិនបង្ហាញអត្រាកំណើនយ៉ាងតិច5%ពីឆ្នាំ2010 ពួកគេនៅតែអាចផ្តល់ភស្តុតាងជាក់លាក់ដែលបង្ហាញថាការខាតបង់របស់ពួកគេ ឬផ្នែកណាមួយនៃការខាតបង់គឺដោយសារតែការកំពប់ប្រេង។ ការកែប្រែនេះកំណត់សារជាថ្មីនូវការគណនាការខាតបង់ដោយការកំពប់ប្រេងដោយប្រើប្រាស់ទិន្នន័យដែលបង្ហាញឱ្យឃើញពីអត្រាកំណើនសេដ្ឋកិច្ចប្រចាំតំបន់ឈូងសមុទ្រលើសពី10%[1]។ (GCCF បានព្យាករណ៍កំណើន10% នៅក្នុងការកំណត់កត្តាពេលអនាគត[2]។) ដោយសារមិនមែនបុគ្គល និងអាជីវកម្មទាំងអស់នឹងជួបប្រទះកម្រិតនៃការវិលត្រលប់រកភាពដើមវិញដូចនេះ អត្រាកំណើនទាប5% ត្រូវបានគេជ្រើសរើស។

**វិធីសាស្ត្រនេះសន្មតថាប្រសិនបើកំណើនរបស់បុគ្គលឬអាជីវកម្មដែលប្តឹងតិចជាង5%ពីឆ្នាំ2010 មិនមែនការខាតបង់ទាំងអស់កើតឡើងដោយសារតែការកំពប់ប្រេងឡើយ ហើយការទូទាត់សងមួយផ្នែកប៉ុណ្ណោះនឹងត្រូវគេផ្តល់ឱ្យ។ សម្រាប់អ្នកប្តឹងដែលបានដាក់ពាក្យប្តឹងជាមួយGCCF ហើយបានប្តឹងទាមទារសំណងបណ្តោះអាសន្នបន្ថែម ការខាតបង់លើសអត្រាកំណើន5%ត្រូវបានគេកំណត់ថាមកពីការកំពប់ប្រេង។ ការខាតបង់ដែលជាប់ទាក់ទងនឹងចំណូលឬកម្រៃរកបានដែលមានអត្រាកំណើនតិចជាង5% ត្រូវបានគេសន្មតថាបណ្តាលមកពីកត្តាផ្សេងពីការកំពប់ប្រេង ហើយ<u>នឹង</u> <u>មិនត្រូវបានគេទូទាត់សងឡើយ។</u>**

**ការកំណត់អត្រា5% គឺមានប្រភពដូចខាងក្រោម៖**

- **កំណត់អត្រាកំណើនព្យាករណ៍ជាមធ្យមសម្រាប់បុគ្គលនិងអាជីវកម្មជាមួយការខាតបង់ឆ្នាំ2010**

អត្រាកំណើន10%នៅក្នុងតំបន់ឈូងសមុទ្រគឺជាការវាយតម្លៃបែបអភិរក្សនៃអត្រាកំណើនជាមធ្យមសម្រាប់បុគ្គលនិងអាជីវកម្មជាមួយការខាតបង់ឆ្នាំ2010។ សូចនាករសេដ្ឋកិច្ចដែលមានផ្តល់នូវមូលដ្ឋានដ៏ល្អសម្រាប់ការអភិវឌ្ឍនៃអត្រាកំណើនបែបអភិរក្សសម្រាប់គោលបំណងនេះ។

- វិស័យទេសចរណ៍

---

[1] សូមមើលរបាយការណ៍ ARPC «*ការវាស់វែងពីឥទ្ធិពលនៃការកំពប់ប្រេងនៅតំបន់ឈូងសមុទ្រជាលក្ខណៈបុគ្គល និងអាជីវកម្ម និងគម្រោងសំណងដែលស្នើ*» បានចុះកាលបរិច្ឆេទ នៅថ្ងៃទី 24 ខែមករា ឆ្នាំ 2011 http://www.gulfcoastclaimsfacility.com/exhibit_c.pdf។

[2] សូមមើល *ឯកសារយោង*នៅលើគេហទំព័រ GCCF – http://www.gulfcoastclaimsfacility.com/exhibit_e.pdf។ Oxford Economics *"ផលប៉ះពាល់នៃការកំពប់ប្រេងឈូងសមុទ្រអាចកើតមានទៅលើវិស័យទេសចរណ៍*» ដែលបានរៀបរៀងសម្រាប់ US Travel Association ខែកក្កដា ឆ្នាំ2010។

- o និន្នាការនៃអត្រានិងចំណូលសណ្ឋាគារក្នុងមួយបន្ទប់ទំនេរបានបង្ហាញថាអត្រាកំណើននៅក្នុងតំបន់ជិតឆ្នេរសមុទ្រគឺប្រហែលជា15%។[3]
  - o ចំណូលពន្ធលក់សម្រាប់ភោជនីយដ្ឋាន (ដែលមាន) បង្ហាញនូវការត្រលប់មករកភាពដើមវិញ ឬការកើនឡើងចំពោះកម្រិតមុនកំពប់ប្រេង។
  - o សូចនាករនៃការចំនាយផ្នែកទេសចរណ៍(ទីដែលមាន)បង្ហាញនូវការត្រលប់មករកភាពដើមវិញ ឬការកើនឡើងចំពោះកម្រិតមុនលេចប្រេង។

- ការនេសាទ
  - o ដែននេសាទសមុទ្ររបស់សហព័ន្ធទាំងមូលត្រូវបានបើកដំណើរការឡើងវិញ។
  - o ស្ទើរតែការនេសាទគ្រប់រដ្ឋទាំងអស់ត្រូវបានបើកឡើងវិញ។
  - o ការកើនឡើងនៅក្នុងការចាប់បង្គានៅក្នុងបួនខែដំបូងនៃឆ្នាំ2011 ហើយ National Marine Fisheries Service រំពឹងការប្រមូលផលត្រីកាម៉ុងព្រុយវែងនឹងនរមួយនៅឆ្នាំ2011។[4]

លើសពីនេះទៅទៀត ការសង្កេតជាប់ទាក់ទងនឹងការវិលទៅរកភាពដើមវិញនៃវិស័យទេសចរណ៍ទាំងនេះគឺស្របគ្នានឹងការវិភាគរបស់យើងនៃការវិលទៅរកភាពដើមវិញនៃវិស័យទេសចរណ៍ដែលចេញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដូចជាគ្រោះថ្នាក់ធម្មជាតិឬហេតុការណ៍រន្ធត់ខ្លាំងដែលមិនអាចព្យាករណ៍បានផ្សេងៗទៀត។[5] ការវិភាគនោះបង្ហាញថាការវិលមករកភាពដើមវិញរយៈពេលខ្លីគឺមានប្រហែល10%។[6]

➢ **កំណត់អត្រាវីកចម្រើននៃអ្នកប្តឹងភាគច្រើននឹងត្រូវគេរំពឹងថាស្មើគ្នាឬលើស។**

---

3 ផ្អែកលើការវិភាគទិន្នន័យពីSmith Travel Research Inc.

[4] ការចាប់បង្គាតាមទិន្នន័យលើដីដែលបានផ្តល់ឱ្យដោយសេចក្តីសង្ខេប NOAA Fisheries Market News Archives ពី Fisheries Statistics Division National Marine Fisheries Service។ អំពីត្រីកាម៉ុងព្រុយវែង សូមមើល *Forecast for the 2011 Gulf and Atlantic Menhaden Purse-Seine Fisheries* ខែមិនា ឆ្នាំ2011 Sustainable Fisheries Branch NMFS Beaufort NC.

[5] សូមមើល *ឯកសារយោង*នៅលើគេហទំព័រ GCCF – http://www.gulfcoastclaimsfacility.com/exhibit_e.pdf ។ Oxford Economics *"ផលប៉ះពាល់នៃការកំពប់ប្រេងឈូងសមុទ្រអាចកើតមានទៅលើវិស័យទេសចរណ៍»* ដែលបានរៀបរៀងសម្រាប់ US Travel Association ខែកក្កដា ឆ្នាំ2010។

[6]ការវិភាគរបស់យើងនៃ«ខ្សែកោងនៃការវិលមករកភាពដើមវិញ»បានបង្ហាញថាបន្ទាប់ពីគ្រោះមហន្តរាយ ឬការរន្ធត់ដែលមិនអាចព្យាករណ៍បាន សេដ្ឋកិច្ចទូទៅខាតបង់20% ពីពេលមុនមានគ្រោះមហន្តរាយ ប៉ុន្តែបន្ទាប់ពីរយៈពេលមួយឆ្នាំ វានឹងឡើងដល់90% នៃកម្រិតមុនពេលមានគ្រោះមហន្តរាយ។ កំណើននេះគឺប្រហែល10%។

យើងមិនសម្មតថាបុគ្គលនិងអាជីវកម្មនឹងមានកំណើន10% ជាមធ្យម – អ្នកខ្លះរីកចម្រើន លឿន ជាងនិងខ្លះទៀតយឺតជាង។ យោងតាមការវិភាគស្ថិតិនៃទិន្នន័យប្រវត្តិសាស្ត្រពីរដ្ឋជាប់ឈូង សមុទ្រ5 ដែលបង្ហាញថាមានអត្រាកំណើនទូទៅ10% យើងមានទំនុកចិត្តថា75% នៃបុគ្គលនិងអាជីវកម្មនឹងរីកចម្រើនយ៉ាងហោចណាស់5.6%។

ការរីកចម្រើន5.6% ត្រូវបានកំណត់ដោយទិន្នន័យចំណូលបុគ្គលប្រចាំត្រីមាសរបស់ការិយាល័យសេដ្ឋកិច្ចសម្រាប់រដ្ឋជាប់ឈូងសមុទ្រនីមួយៗពីត្រីមាសទីមួយនៃឆ្នាំ2000 ទៅត្រីមាសទីបួននៃឆ្នាំ2010 (ទិន្នន័យត្រីមាសថ្មីបំផុតគឺមាន)។ នៅក្នុងអំឡុងពេលនេះ នៅឈូងសមុទ្រនៃរដ្ឋទាំងប្រាំការវិភាគបង្ហាញថាប្រសិនបើអត្រាកំណើនជាមធ្យមគឺ10%ដែល75%នៃបុគ្គលនិងអាជីវកម្មកើនយ៉ាងតិច5.6%។ ដើម្បីអភិរក្សយើងបានបញ្ចុះពី5.6%ទៅ5%។

អ្នកប្តឹងទាមទារចំណូល/កម្រៃ «ពិតប្រាកដ» សម្រាប់ឆ្នាំ2011គឺត្រូវបានសន្មតថាមានភាពរីកចម្រើនមិនតិចជាង 5%ពីឆ្នាំ2010 លើកលែងតែអ្នកប្តឹងទាមទារអាចផ្តល់នូវភស្តុតាងដែលការខាតបង់ «ពិតប្រាកដ» អាចត្រូវបានគេពន្យល់កើតឡើងដោយសារតែការកំពប់ប្រេង។ វិធីសាស្ត្រនេះឆ្លុះបញ្ចាំងនូវការរំពឹងគិតថានៅក្នុងស្ថានភាពដែលឱកាសសម្រាប់ការត្រលប់មករកភាពដើមវិញមានភាពប្រសើរឡើងគួរកត់សម្គាល់ វាមានហេតុផលសមរម្យដើម្បីរំពឹងគិតថាចំណូលឬកម្រៃពិតប្រាកដរបស់អ្នកប្តឹងទាមទារនៅឆ្នាំ2010នឹងបង្ហាញនូវការប្រសើរឡើងជាអប្បបរមាខ្លះ។

## II. ការទាមទារសំណងបណ្តោះអាសន្ននៃអ្នកប្តឹងទាមទារគ្មានការងារធ្វើ

ការវិភាគស្ថិតិនៃភាពគ្មានការងារធ្វើនៅរដ្ឋជាប់ឈូងសមុទ្រសរុបថារយៈពេលគ្មានការងារធ្វើជាមធ្យមនៅក្នុងរដ្ឋជាប់ឈូងសមុទ្រគឺប្រហែល22សប្តាហ៍[7]។ ការសិក្សាពីរយៈពេលនៃភាពគ្មានការងារធ្វើបានបង្ហាញឱ្យឃើញថាប្រហែលជា 95% នៃបុគ្គលដែលគ្មានការងារធ្វើនៅរដ្ឋជាប់ឈូងសមុទ្រនឹងមានការងារធ្វើឡើងវិញបន្ទាប់ពី78 សប្តាហ៍[8]។ យោងតាមស្ថិតិខាងលើ បុគ្គលដែលមានសិទ្ធិទទួលគួរត្រូវបានគេបន្តសងប្រាក់ឱ្យតាមរយៈដំណើរការសំណងបណ្តោះអាសន្នសម្រាប់រយៈពេលអតិបរមា

---

[7] U.S. Bureau of Labor Statistics Geographic Profile of Employment and Unemployment តារាង 26 2009 (http://www.bls.gov/opub/gp/pdf/gp09_26.pdf)។

[8] Carrington William «*ការបាត់បង់ប្រាក់ឈ្នួលសម្រាប់កម្មករដែលគេត្រូវជំនួស៖ តើវាគឺក្រុមហ៊ុនមែនឬដែលមានបញ្ហា?*» Journal of Human Resources 28(3) Summer 1993៖ 435-462; Abbring Jaap et al *"Displaced Workers in the United States and the Netherlands"* Working Paper August 1998; Bowlus & Vilhuber *"Displaced workers early leavers and re-employment wages"* U.S. Census Bureau Technical Paper No. TP-2002-18 November 2002 (citing Ruhm Christopher *"Advance Notice and Postdisplacement Joblessness"* Journal of Labor Economics 10(1) 1992៖ 1-32.

78សប្តាហ៍ពីថ្ងៃដែលគ្មានការងារធ្វើដោយសារតែការកំពប់ប្រេងដូចដែលមានចែងក្នុងឯកសារបញ្ជាក់ផ្តល់ដោយអ្នកប្តឹងទាមទារ។

## III. រូបមន្តការទូទាត់សំណងសម្រាប់អ្នកប្តឹងទាមទារដែលគ្មានការខាតបង់នៅឆ្នាំ2010

សម្រាប់អ្នកប្តឹងទាមទារដែលមិនមានការខាតបង់នៅឆ្នាំ2010 ប៉ុន្តែអាចបង្ហាញពីការខាតបង់នៅឆ្នាំ2011 ដោយសារការកំពប់ប្រេង ការទូទាត់សំណងមានពីរប្រភេទ៖

1. ការខាតបង់ឆ្នាំ2011 ដែលយកជាការបាន[9] និង

2. ការផ្តល់ចុងក្រោយស្មើនឹងការខាតបង់នៅឆ្នាំ2011 បូកកត្តារួមផ្សំនាពេលអនាគតនៃការខាតបង់ឆ្នាំ2011 ដែលនឹងត្រូវបានគេកំណត់តាមករណីនីមួយៗ។

ការកំណត់ពីកត្តានាពេលអនាគតសម្រាប់អ្នកប្តឹងទាមទារទាំងនេះគឺអាស្រ័យលើការស្រាវជ្រាវដូចគ្នាដែលជាមូលដ្ឋានការផ្តល់ចុងក្រោយសម្រាប់អ្នកប្តឹងទាមទារការខាតបង់ឆ្នាំ2011។ ARPC បានផ្តល់នូវការពិពណ៌នានៃការស្រាវជ្រាវនេះនៅក្នុងឯកសារដែលបានបោះពុម្ពថ្មីៗដែលបានលំអិតពីផ្លូវនៃការត្រលប់មករកភាពដើមវិញសម្រាប់អ្នកប្តឹងទាមទារការខាតបង់នៅឆ្នាំ2011។[10] ជាសរុបទិន្នន័យពីគ្រោះមហន្តរាយពីមុនបង្ហាញថាប្រហែលជា70%នៃការត្រលប់មករកភាពដើមឡើងវិញគឺត្រូវបានគេរំពឹងថាកើតមានឡើងនៅឆ្នាំទីមួយហើយ30% នៅឆ្នាំបន្ទាប់។ អ្នកប្តឹងទាមទារជាមួយដែលមានការបញ្ជាក់ពីការខាតបង់ឆ្នាំ 2011 ប៉ុន្តែមិនមានសម្រាប់ការខាតបង់នៅឆ្នាំ2010 គឺជាប្រភេទពិសេសមួយ។ អ្នកប្តឹងទាមទារទាំងនេះជួបប្រទះការខាតបង់ដំបូងរបស់ខ្លួននៅក្នុងអំឡុងពេលនៃការត្រលប់ទៅរកភាពដើមវិញហើយដូច្នេះហើយតម្រូវឱ្យមានការពិនិត្យនិងវិភាគតាមករណីរបស់បុគ្គលនីមួយៗ។

## IV. រូបមន្តនៃការទូទាត់សំណងសម្រាប់អ្នកប្តឹងទាមទារដែលគ្មានចំណូលនៅឆ្នាំ 2010

---

[9] សូមមើល *វិធានគ្រប់គ្រងជម្រើសទូទាត់សំណងចុងក្រោយ សិទ្ធិអាចទទួលយកបាននិងលក្ខខណ្ឌជាក់ស្តែង និងវិធីសាស្ត្រនៃការទូទាត់ចុងក្រោយ* ទំព័រ 3 *ការគណនានៃរង្វាន់សម្រាប់ការទូទាត់សំណងបណ្តោះអាសន្ន និងចុងក្រោយ*៖ http://www.gulfcoastclaimsfacility.com/FINAL_RULES.pdf

[10] សូមមើល *វិធានគ្រប់គ្រងជម្រើសទូទាត់សំណងចុងក្រោយ សិទ្ធិអាចទទួលយកបាននិងលក្ខខណ្ឌជាក់ស្តែង និងវិធីសាស្ត្រនៃការទូទាត់ចុងក្រោយ*ឯកសារភ្ជាប់B។ ការឆ្លើយតបចំពោះយោបល់ស្តីពីប្រភពនិងការគណនាការខូចខាតនាពេលអនាគត ទំព័រ13៖ http://www.gulfcoastclaimsfacility.com/FINAL_RULES_B.pdf

អ្នកប្ដឹងទាមទារដែលគ្មានចំណូលនៅឆ្នាំ2010 គឺមិនថាតែជាបុគ្គលទាំងឡាយណាដែលមិនមានការងារធ្វើសម្រាប់រយៈពេលពេញមួយឆ្នាំ(ទាំងមុននិងក្រោយការកំពប់ប្រេង)ឬអាជីវកម្មទាំងឡាយណាដែលគ្មានការលក់ពេញមួយឆ្នាំ(ទាំងមុននិងក្រោយការកំពប់ប្រេង)។ GCCF ជឿជាក់ថាមានអ្នកប្ដឹងទាមទារមួយចំនួនតូចប៉ុណ្ណោះដែលត្រូវទទួលបានការទូទាត់ប្រាក់សំណងទំនងបង្ហាញខ្លួននៅក្នុងកាលៈទេសៈដូចនេះ ហើយកាលៈទេសៈទាំងនេះគឺមានភាពដោយឡែកដែលគ្មានគោលការណ៍ជាទូទៅណាមួយអាចយកមកអនុវត្តបានឡើយ។ ដូច្នេះ GCCF នឹងត្រួតពិនិត្យករណីទាំងអស់នេះដោយឡែកៗពីគ្នា។